# សត្វលា

(បទពំនោល)



នេះបទកំណាត់ពណ៌នា ថ្លែងពីសត្វលា ម្ចាស់វាបណ្ដើរទៅផ្សារ។
ខ្នងលាដឹកជាលដាក់ផ្កា ស្អាងស្អាតអស្ចារ្យ គន្ធាក្រអូបសព្វសាយ។
អស់ជនតាមផ្លូវទាំងឡាយ ងាកមើលប្រញាយ ខ្វះឆ្ងាយវាចាសរសើរ។
លាខំធ្វើឫកគ្រាន់បើ កែក្រាយដំណើរ ព្រោះស្មានគេសរសើរវា។
សប្បាយចិត្តឥតគណនា មុខរីកដូចរាហ៊ុ លីលាដូចអង្គក្សត្រា។
កុំតែម្ចាស់ឃាត់ក្រៃណា ម៉្ងៃះលាយាត្រា ហួសផ្សារក៏មិនឈប់ដែរ។
អ្នកផ្សារទិញផ្កាហូរហែ ម្ចាស់លាប្រមែ ប្រមូលប្រាក់ដាក់ក្នុងថង់។
លុះវេលាថ្ងៃជិតត្រង់ គាត់មិនអែអង់ តម្រង់ទៅផ្ទះលក់ដី។
ទិញដាក់ពេញជាលទាំងពីរ មុននឹងម្ចាម្ចី លើកដីផ្ទុកលើខ្នងលា។
អ្នកផងតាមដងមាគ៌ា ងាកចេញគ្រប់គ្នា ពេលលាដើរដល់ជិតនៃ។
លានឹកទាស់ក្នុងហឫទ័យ ដីស្អុយពេកក្រៃ ឱ្យវាអាប់រាសីអស់។
តូចចិត្តរឹតនឹកស្រណោះ កាលគ្រាដែលមនុស្ស ស្រាយស្រស់ញញឹមដាក់វា។
នេះរឿងនិទានពីលា លោកអ្នកនានា អាចយល់ឫសគល់ហេតុការណ៍។
បានជាគតិយ៉ាងណា ស្រេចលើប្រាជ្ញា និងការពិចារណ៍ទៅអើយ៕



តាមលំនាំពុទ្ធនិទាន
ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី